# អែលឌើរស្ទីវិនសុនទៅទស្សនាប្រទេសឈីលី






អែលឌើរ ហ្គែរី អ៊ី ស្ទីវិនសុន និងស៊ីស្ទើរ ឡេស្សា ស្ទីវិនសុន បានធ្វើដំណើរជាមួយប្រធាន រ័សុល អិម ណិលសុន និងស៊ីស្ទើរ វិនឌី ណិលសុន ទៅប្រទេសឈីលីសម្រាប់ព្រឹត្តិការណ៍ដ៏សំខាន់មួយ ។ ព្រះវិហារបរិសុទ្ធថ្មីមួយត្រូវបានឧទ្ទិសឆ្លងនៅក្នុងទីក្រុងខនសិបសិន !

ព្រះវិហារបរិសុទ្ធថ្មីដ៏ស្រស់ស្អាតនេះគឺជាព្រះវិហារបរិសុទ្ធទីពីរដែលត្រូវសាងសង់នៅក្នុងប្រទេសឈីលី ហើយជាព្រះវិហារបរិសុទ្ធទី ១៨ នៅក្នុងអាមេរិកខាងត្បូង ។



កុមារបានមកជាមួយឪពុកម្ដាយរបស់ពួកគេដើម្បីស្ដាប់ប្រធានណិលសុនអធិស្ឋានពិសេសមួយដើម្បីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ។



ឡារ៉ា និង អាលីសៀ អូ បានជួយដាក់ថ្មចុងក្រោយគេនៅខាងក្រៅព្រះវិហារបរិសុទ្ធ ។ នេះត្រូវបានហៅថា ថ្មជ្រុងនៃព្រះវិហារបរិសុទ្ធ ។ បន្ទាប់មកព្រះវិហារបរិសុទ្ធរួចរាល់ដើម្បីឧទ្ទិសឆ្លង ។



មានការរញ្ជួយដីជាច្រើនកើតឡើងនៅក្នុងប្រទេសឈីលី ។ ព្រះវិហារបរិសុទ្ធ ខនសិបសិន ឈីលី មានគ្រឹះយ៉ាងពិសេសដើម្បីរក្សាវាពីការរងគ្រោះថ្នាក់ ប្រសិនបើមានផែនដីរញ្ជួយកើតឡើងនៅទីនោះ ។




ឥឡូវនេះ សមាជិកស័ក្តិសមនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ អាចចូលទៅខាងក្នុងព្រះវិហារបរិសុទ្ធ ដើម្បីផ្សារភ្ជាប់ក្រុមគ្រួសារពួកគេ ហើយបម្រើតាមរយៈការធ្វើបុណ្យជ្រមុជទឹកក្នុងព្រះវិហារបរិសុទ្ធ !

រូបថតខាងលើ ខាងស្ដាំ ខាងក្រោមថតដោយ ជែហ្វ្រី ឌី អាល់រ៉េត *DESERET NEWS*